# រាជបណ្ឌិត្យសភាកម្ពុជា

# មរតក និងតម្លៃឫស្សី
# នៅឧទ្យានរាជបណ្ឌិត្យសភាកម្ពុជា តេជោសែន ឫស្សីត្រឹប




ផែនទីបង្ហាញពីវិសាលភាពឫស្សីដុះក្នុងឧទ្យានរាជបណ្ឌិត្យសភាកម្ពុជា តេជោសែន ឫស្សីត្រឹប


វិទ្យាស្ថានវប្បធម៌ និងវិចិត្រសិល្បៈ



២០១៨

# មរតក និង តម្លៃឫស្សី
# នៅឧទ្យានរាជបណ្ឌិត្យសភាកម្ពុជា តេជោសែន ឫស្សីត្រឹប

*ដោយ៖ លោកបណ្ឌិត **ផុន កសិកា**[១], លោក **ប្រេង ពិសិដ្ឋ**[២], លោក **នៅ សាមន**[៣] និងកញ្ញា **តាកេត ស័កដា**[៤]*

*១. អនុប្រធានវិទ្យាស្ថានវប្បធម៌ និងវិចិត្រសិល្បៈនៃរាជបណ្ឌិត្យសភាកម្ពុជា;*

*២. លេខាអចិន្ត្រៃយ៍នៃវិទ្យាស្ថានវប្បធម៌ និងវិចិត្រសិល្បៈនៃរាជបណ្ឌិត្យសភាកម្ពុជា;*

*៣. ឧទ្យាននុរក្សនៃឧទ្យានរាជបណ្ឌិត្យសភាកម្ពុជាតេជោសែន ឫស្សីត្រឹប;*

*៤. មន្ត្រីស្ម័គ្រចិត្តនៃវិទ្យាស្ថានវប្បធម៌ និងវិចិត្រសិល្បៈនៃរាជបណ្ឌិត្យសភាកម្ពុជា*



*ព្រៃឫស្សីដុះក្នុងបណ្តុំទួលឡស្វដែកត្រពាំងឫស្សីត្រឹប*

## សេក្តីផ្តើម

ប្រទេសកម្ពុជាស្ថិតក្នុងតំបន់អាស៊ីអាគ្នេយ៍ ក្នុងតំបន់ត្រូពិច ក្តៅហើយសើម ព្រមទាំងស្ថិតនៅក្នុងតំបន់អាស៊ីមូសុង សម្បូរភ្លៀង ដែលបង្កលក្ខណៈល្អប្រសើរដល់រុក្ខជាតិ និងដំណាំគ្រប់ប្រភេទលូតលាស់បានល្អ។ ប្រទេសកម្ពុជាសម្បូរទៅដោយជីវសាស្ត្រចម្រុះ និងមានព្រៃបៃតងនៅតំបន់ទំនាបធំជាងគេទី៣នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ដែលមានពូជរុក្ខជាតិរហូតដល់២៣០០ពូជ[1]។

ឫស្សីក៏ជាពូជរុក្ខជាតិមួយប្រភេទនៅប្រទេសកម្ពុជាដែរ ហើយដុះនៅគ្រប់តំបន់ទាំងអស់ក្នុងប្រទេស។ ឫស្សីគឺជា«តចសារជាតិ»[2]មួយប្រភេទ ដុះទំពាំងចេញជាគុម្ព ដើមមានថ្នាំង មានច្រើនប្រភេទ ដូចជាឫស្សីស្រុក

---

[1] https://www.usaid.gov/cambodia/environment-and-global-climate-change (14 October 2018)

[2] បើតាមវចនានុក្រមអក្ខរាវិរុទ្ធនៃភាសាខ្មែរ ចេញផ្សាយដោយវិទ្យាស្ថានភាសាជាតិ នៃរាជបណ្ឌិត្យសភាកម្ពុជា, ២០១៥, អានថា /តាច់-ចាក់-សា-រ៉ៈ-ជាត/ (បា.,សំ. ត្វក្សារជាតិ) ជាជាតិឈើដែលមានសំបកជាខ្លឹមឬមានខ្លឹមនៅត្រង់សំបក ដូចយ៉ាងឫស្សី, ត្នោត, ដូងជាដើម ។

ឫស្សីព្រៃ ឫស្សីរលៀក[3]។ ឫស្សីមានអត្ថប្រយោជន៍ច្រើនបែបយ៉ាង រាប់ទាំងទំពាំង ដើម និងស្លឹក ពិសេសពេលថ្មីនេះ ដើមឫស្សីអាចយកធ្វើជាធ្យូងបានដែរ[4]។ ដើមឫស្សីមានប្រយោជន៍សម្រាប់តម្រូវការប្រើប្រាស់ក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋក្នុងប្រទេសកម្ពុជា។ ដើមឫស្សីអាចយកទៅធ្វើជាគ្រឿងសំណង់ផ្ទះ, គ្រឿងសង្ហារិម (គ្រែ តុ ទូ ជាដើម), ឧបករណ៍នេសាទ (លប ទ្រូ លាន់ ជុច ព្រួល ជាដើម), ឧបករណ៍សម្រាប់ដាក់វត្ថុផ្សេង (ដូចជា កញ្ជើ ចង្អេរ ជាល ល្អី អង្រុតក្រុងមាន់ បំពង់ទឹកត្នោត កន្ត្រងប្រហុក ទ្រនាប់ឆ្នាំង), ឧបករណ៍ភ្លេង (១. រនាតឯក រនាតធុង រនាតថោង ខ្លុយ ប៉ីពក គែន ក្លុយ គងឫស្សី) និងគ្រឿងអនុស្សាវរីយ៍។ល។ ចំណែកនៅប្រទេសចិនវិញ ដោយសារមានឫស្សីច្រើនជាងគេក្នុងពិភពលោក គេហៅប្រទេសចិនថាជា «អាណាចក្រឫស្សី» មានពូជឫស្សីលើសពី៤០០ពូជ[5] ព្រមទាំងមានអត្ថប្រយោជន៍រហូតដល់២៨មុខ[6]។

ឧទ្យានរាជបណ្ឌិត្យសភាកម្ពុជា តេជោសែន ឫស្សីត្រឹប បង្កើតឡើងដោយព្រះរាជក្រឹត្យលេខ នស/រកត/០៤១៤/៤៣៦ ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១៤ មានផ្ទៃដីក្រឡាចំនួន១១៤៣៥ហិកតា[7] ដែលមានទីតាំងស្ថិតក្នុងឃុំឆែប១ និងឃុំឆែប២ ស្រុកឆែប ខេត្តព្រះវិហារ។ ថ្មីៗនេះ មន្ត្រីស្រាវជ្រាវនៃវិទ្យាស្ថានវប្បធម៌ និងវិចិត្រសិល្បៈ ដោយមានការចូលរួមពីមន្ត្រីឧទ្យានរាជបណ្ឌិត្យសភាកម្ពុជា តេជោសែន ឫស្សីត្រឹប បានសិក្សាស្រាវជ្រាវ និងរុករកស្ថានីយបុរាណនៅឧទ្យានរាជបណ្ឌិត្យសភាកម្ពុជា តេជោសែន ឫស្សីត្រឹប បានរកឃើញស្ថានីយបុរាណ និងវត្ថុបុរាណ មានដូចជា ទួលសន្លុង (ទួលឡស្លដែក) ចំនួន៥៤ ត្រពាំងសន្លុងចំនួន២៩ ត្រពាំងបុរាណចំនួន៦៦ និងបុរាណវត្ថុមួយចំនួន ដូចជាឧបករណ៍ថ្មរំលីងក្នុងយុគថ្មរំលីង (ដែលមានអាយុកាល២០០០ឆ្នាំមុនគ្រិស្តសករាជ) កុលាលភាជន៍ ត្រឡែកតូច ត្រឡែកធំ ដុំថ្មភក់ប្រើក្នុងការស្មិតដែក ផ្លែចបជីក ផ្លែដឹង ចង្កំដងកាំបិត ដងកាំបិត និងដែកគោលជាដើម[8]។ ក្រៅពីធនធានដែលជាមរតកវប្បធម៌ ឧទ្យានរាជបណ្ឌិត្យសភាកម្ពុជា តេជោសែន ឫស្សីត្រឹប នៅមានធនធានជាមរតកធម្មជាតិ ដែលគ្របដណ្តប់ទាំងក្នុងព្រៃស្រោង និងព្រៃរបោះ មានដើមឈើធំៗ (ស្រឡៅ ត្រាច បេង ធ្នឹក កកោះ ធ្នង់ នាងនួន។ល។) និងប្រភេទឈើដូចជាដើមរកា ខ្វាវ ត្រសេក ដើមជ្រៃ ដើមច្រេះ ដើមធ្លក ដើមចំបក់ ដើមខ្នុំ ដើមក្រឡាញ់ ដើមពពេល ដើមស្តៅ ដើមព្រីង ដើមត្រកៀបក្តាម ដើមរវាង ដើមរំពុក ដើមកណ្តោល ដើមម៉ាំង ដើមប៉ប្រេក ដើមធ្លូ ដើមទ្វារ ដើមប្រាំតម្លឹង វល្លិស្លែង វល្លិចារ វល្លិផ្តៅ[9] ។ល។

---

[3] វចនានុក្រមខ្មែរ, បោះពុម្ពលើកទី៥

[4] http://www.geres.eu/en/development-of-a-sustainable-bamboo-charcoal-production-center ( 14 October 2018)

[5] http://www.chinatoday.com/culture/bamboo_and_chinese/bamboo_and_chinese_culture.htm (15 October 2018)

[6] https://globalfoodbook.com/28-incredible-benefits-of-the-bamboo-plant (15 October 2018)

[7] ព្រះរាជក្រឹត្យស្តីពី *ការបង្កើត "ឧទ្យានរាជបណ្ឌិត្យសភាកម្ពុជា តេជោសែន ឫស្សីត្រឹប"* លេខ នស/រកត/០៤១៤/៤៣៦ ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១៤

[8] នូ ចាន់សុភី, ផុន កសិកា, ប្រែង ពិសិដ្ឋ... "*សម្បត្តិបេតិកភណ្ឌវប្បធម៌រូបី និងមរតកវប្បធម៌អរូបី នៅឧទ្យានរាជបណ្ឌិត្យសភាកម្ពុជា តេជោសែន ឫស្សីត្រឹប និងការសិក្សាអង្កេតមរតកវប្បធម៌អរូបីដូចគ្នានៅខេត្តកំពង់ធំ ខេត្តស្ទឹងត្រែង និងខេត្តក្រចេះ*", វិទ្យាស្ថានវប្បធម៌ និងវិចិត្រសិល្បៈ, រាជបណ្ឌិត្យសភាកម្ពុជា, ២០១៨។

[9] បទសម្ភាសន៍លោក សួង សាត ប្រជាពលរដ្ឋរស់នៅក្នុងភូមិឆែបលិច ឃុំឆែប១ ស្រុកឆែប ខេត្តព្រះវិហារ។



រូបលេខ១៖ ព្រៃស្រឡៅជុំះក្នុងឧទ្យាន



រូបលេខ២៖ ព្រៃស្រោងក្នុងឧទ្យានរាជបណ្ឌិត្យសភាកម្ពុជា

## I. មរតកឫស្សីនៅឧទ្យានរាជបណ្ឌិត្យសភាកម្ពុជា តេជោសែន ឫស្សីត្រឹប

### ១- ស្ថាននាមទាក់ទងនឹងពាក្យ «ឫស្សី»

ក្នុងការប្រសិទ្ធនាម *ឧទ្យានរាជបណ្ឌិត្យសភាកម្ពុជាតេជោសែនឫស្សីត្រឹប* គឺមានពាក្យ «ឫស្សីត្រឹប» ជាពាក្យគន្លឹះមួយសម្រាប់សម្គាល់ទីតាំងនៃឧទ្យាននេះ។ អ្នកស្រុកឆែប ខេត្តព្រះវិហារ បានស្គាល់យ៉ាងច្បាស់អំពីទីស្ថាននេះ។

តាមការសិក្សាស្រាវជ្រាវ យើងបានដឹងថា សម្រាប់ប្រជាជនរស់នៅភូមិដងផ្លិត *ឫស្សីត្រឹប* សំដៅដល់ដើមឫស្សីដែលដុះនៅតំបន់ត្រឹប(តំបន់មានស្រះឬត្រពាំងបី [10]) ពោលគឺ *ឫស្សីមកពីត្រឹប*។ រាល់តម្រូវការប្រើប្រាស់ដើមឫស្សី (និងទំពាំងសម្រាប់ទទួលទាន) ប្រជាជនរស់នៅភូមិដងផ្លិតតែងតែទៅកាប់ពីតំបន់ត្រឹប ដែលជាតំបន់មានដើមឫស្សីដុះច្រើនជាងគេ។ ជាមួយគ្នានោះ ក្នុងតំបន់ដែលមានដុះដើមឫស្សីច្រើននៅតំបន់ត្រឹបនោះ ក៏មានស្រះឬត្រពាំងមួយឈ្មោះថា *ត្រពាំងឫស្សី* ដែរ។ ដូច្នេះ ពាក្យ «ឫស្សី» នៅក្នុងនាមរបស់ឧទ្យាននេះ គឺបានបញ្ជាក់អំពីស្ថានភាពក្នុងតំបន់ឧទ្យានដែលមានដុះដើមឫស្សីផង និងបានបញ្ជាក់អំពីស្ថាននាមផង (ស្រះឬត្រពាំងឫស្សី)។

ក្រៅពីស្ថាននាម *ត្រពាំងឫស្សី* មានស្ថាននាមផ្សេងទៀតនៅក្នុងឧទ្យានដែលមានពាក្យ «ឫស្សី» ហើយដែលស្ថាននាមនោះសុទ្ធសឹងមានដុះដើមឫស្សីជាក់ស្តែង ដូចជា ស្ថាននាម ត្រពាំងឫស្សីបល្ល័ង្គ ជាដើម។

### ២- ឫស្សីនិងសន្លង

ក្រៅពីរុក្ខជាតិតូច ធំផ្សេងៗ នៅឧទ្យានរាជបណ្ឌិត្យសភាកម្ពុជាក៏មានរុក្ខជាតិឫស្សីដុះយ៉ាងច្រើនដែរ ពិសេសនោះ ឫស្សីដុះក្នុងតំបន់បណ្តុំទួលសន្លងស្លដែកតែម្តង។ លក្ខណៈពិសេសដោយឡែកមួយរបស់ឫស្សីនៅឧទ្យានរាជបណ្ឌិត្យសភាកម្ពុជា គឺដុះនៅតែក្នុងតំបន់បណ្តុំទួលសន្លងស្លដែក ដែលមានចំនួន៥បណ្តុំទួលសន្លង ហើយបណ្តុំទួលសន្លងស្ទើរតែទាំងអស់មានឫស្សីដុះច្រើន លើកលែងតែបណ្តុំទួលសន្លងភូមិកំបុតចាស់ដែលមិនមានឫស្សីដុះ។

តាមរយៈការសិក្សាធ្វើផែនទីស្ថានីយបង្ហាញពីវិសាលភាព និងបរិមាណនៃឫស្សីដុះក្នុងឧទ្យានរាជបណ្ឌិត្យសភាកម្ពុជាបង្ហាញថា ឫស្សីដុះក្នុងបណ្តុំទួលសន្លងត្រពាំងត្រឹប និងក្នុងបណ្តុំទួលសន្លងត្រពាំងឫស្សីត្រឹប អាចមានទំហំរហូតដល់ ៦៤ ហិកតា។ ទោះបីក្នុងបណ្តុំទួលសន្លងទាំង២មានឫស្សីច្រើន ប៉ុន្តែនៅមានប្រភេទដើមឈើតូច ធំ និងរុក្ខជាតិផ្សេងៗទៀតដុះលាយឡំផងដែរ។ ចំណែកឫស្សីក្នុងបណ្តុំទួលសន្លងត្រពាំងក្រសាំងដុះក្នុងទំហំដីត្រឹមតែ ៥ហិកតា ហើយដុះរង្វើលៗពីគ្នា។ រីឯនៅក្នុងបណ្តុំទួលសន្លងត្រពាំងឫស្សីបល្ល័ង្គវិញ ឫស្សីដុះក្នុងទំហំដីប្រមាណ ៨ ហិកតា ហើយដុះរង្វើលពីគ្នា ប៉ុន្តែញឹកស្កះនៅជុំវិញត្រពាំងឫស្សីបល្ល័ង្គ។

---

[10] តំបន់មួយដែលមានស្រះឬត្រពាំងបី គឺ ស្រះឬត្រពាំងត្រឹប(ត្រពាំងមានទំហំធំ ស្ថិតនៅខាងលិចថ្នល់), ត្រពាំងឫស្សីត្រឹបលើ (ស្រះស្រី) និងត្រពាំងឫស្សីត្រឹបក្រោម (ស្រះប្រុស) ដែលស្ថិតនៅខាងកើតថ្នល់។ តំបន់នេះស្ថិតនៅសងខាងផ្លូវនិងស្ទើរជាចំណុចកណ្តាលរវាងថ្នល់ពីផ្លូវជាតិលេខ ៦៤ ទៅភូមិដងផ្លិត។




ផែនទីបង្ហាញពីវិសាលភាពឫស្សីដុះក្នុងឧទ្យានរាជបណ្ឌិត្យសភាកម្ពុជា តេជោសែន ឫស្សីត្រឹប



រូបលេខ៣៖ ព្រៃឫស្សីដុះក្នុងបណ្តុំទួលឡស្លដែកត្រពាំងត្រឹប



រូបលេខ៤៖ ព្រៃឫស្សីដុះក្នុងបណ្ដុំទួលឡស្លដែកត្រពាំងឫស្សីត្រឹប

**៣- ប្រភេទឫស្សី**

តាមការសិក្សាស្រាវរកឃើញថា នៅឧទ្យានរាជបណ្ឌិត្យសភាកម្ពុជា តេជោសែន ឫស្សីត្រឹប មានឫស្សីចំនួន ៤ប្រភេទ ដូចខាងក្រោម៖

៣.១. ឫស្សីឃ្លៃលលក

ដើមមានតូចៗ ដុះស្អេកស្កះ ញឹកប្រគរគ្នា ចាប់ពីគល់ទៅចុងថ្នាំងរបស់វាខ្លី។ គេយកឫស្សីឃ្លៃលលកធ្វើដងចបកាប់ និងដងចបជីក។ ទំពាំងនៃប្រភេទឫស្សីឃ្លៃលលកនេះមានរសជាតិផ្អែម មិនហាងដូចទំពាំងឫស្សីប្រភេទផ្សេងៗទេ។





រូបលេខ៥ និង៦៖ ឫស្សីឃ្លៃលលក

### ៣.២. ឫស្សីទ្រនំមាន់

ដើមមានទំហំធំៗ ដុះរង្វើលឃ្លាតពីគ្នាប្រវែងពី ១៥ស.ម. ទៅ ២០ស.ម.។ ចំណែកឯថ្នាំងរបស់វាវិញ មានសភាពញ្រឹក មានទំហំធំល្មម គ្មានបន្លាទេ។ គេយកដើមរបស់វាទៅធ្វើជាចម្រឹងរបង របាររបង និងយកធ្វើផ្ទះ។ល។ ទំពាំងនៃឫស្សីប្រភេទនេះមានរសជាតិដូចទៅនឹងទំពាំងឃ្លែលលកដែរ តែមានរោមនៅនឹងសម្បករបស់វាច្រើន។




រូបលេខ៧ និង៨៖ ឫស្សីទ្រនំមាន់

### ៣.៣. ឫស្សីសាញ

ដើមមានទំហំតូច ថ្នាំងញ្រឹក ចាក់ស្រែះចូលគ្នា មានកំពស់ប្រហែល៣ម៉ែត្រ ប្រវែងមុខកាត់ពី១៥ស.ម. ទៅ ២០ស.ម.។ ទំពាំងនៃឫស្សីប្រភេទនេះមិនអាចបរិភោគបានទេ។



រូបលេខ៩៖ ឫស្សីសាញ

### ៣.៤. ឫស្សីធម្មតា

ដើមមានទំហំធំ ហើយចាក់ស្រែះចូលគ្នាជាគុម្ពៗ ដែលមានមុខកាត់១៥ស.ម. ទៅ ២០ស.ម. ហើយមានសភាពស្កុក។ ដើមរបស់វាអាចយកទៅធ្វើជា ទ្រូ លប ឈ្នាង អង្រុត ព្រួល កន្ត្រក គ្រុះ ចង្អេរ ក្រង់ និងអាចយកធ្វើជាគ្រឿងសំណង់ផ្ទះបាន។ ទាក់ទងប្រយោជន៍សម្រាប់អាហារវិញ មនុស្សចាស់សម័យដើមតែងយកផ្កាឫស្សីចាស់ៗទៅបុកធ្វើជាបាយ ជំនួសអង្ករបាន ប្រសិនបើគ្មានអង្ករសម្រាប់បរិភោគ។ រីឯទំពាំង គេយកធ្វើជាបន្លែសម្រាប់បរិភោគ ស្លសម្លរ ធ្វើជ្រក់ទំពាំងជូរ ឬទំពាំងប្រៃ។ល។



រូបលេខ១០៖ ឫស្សីធម្មតា

## II- តម្លៃឫស្សីនៅឧទ្យានរាជបណ្ឌិត្យសភាកម្ពុជា តេជោសែនឫស្សីត្រឹប

ឫស្សីនៅឧទ្យានរាជបណ្ឌិត្យសភាកម្ពុជា តេជោសែន ឫស្សីត្រឹប កំពុងដើរតួនាទីសំខាន់មួយ និងបំពេញតម្រូវការរបស់ប្រជាពលរដ្ឋក្នុងសហគមន៍ ពិសេសប្រជាពលរដ្ឋក្នុងឃុំឆែប១ និងឃុំឆែប២ និងប្រជាពលរដ្ឋមកពីស្រុក ខេត្តឆ្ងាយៗទៀតផង ដូចជាមកពីខេត្តកំពង់ធំ ជាដើម។ ចំណែកឯអង្គភាពឧទ្យានរាជបណ្ឌិត្យសភាកម្ពុជា តេជោសែន ឫស្សីត្រឹប នៅមិនទាន់ប្រមូលផលពីឫស្សីទាំងអស់នោះសោះឡើយដោយហេតុថាទុកឱកាសឱ្យសហគមន៍ទាញប្រយោជន៍ពីអនុផលព្រៃឈើដូចដែលពួកគេធ្លាប់អនុវត្តកន្លងមក[11]។ ជារៀងរាល់ឆ្នាំ ជាពិសេសនៅរដូវប្រមូលផលទំពាំង សហគមន៍ក្នុងតំបន់ស្រុកឆែប និងប្រជាពលរដ្ឋមកពីស្រុកឆ្ងាយៗមកជីកទំពាំងជាលក្ខណៈគ្រួសារផង និងអាចជាលក្ខណៈលក់ដូរផងដែរ។ ក្រៅពីផលទំពាំង សហគមន៍ក្នុងស្រុកឆែបតែងមកកាប់ដើមឫស្សីយកទៅប្រើប្រាស់សម្រាប់តម្រូវការរបស់ពួកគេ ដូចជា ទ្រូ លប ឈ្នាង អង្រុត ព្រួល កន្ត្រក គ្រុះ ចង្អេរ ក្រង់ និងគ្រឿងសំណង់ផ្ទះ ពិសេសពួកគេក៏យកឫស្សីធម្មតាធ្វើនំក្រឡានដែរ[12]។

អត្ថប្រយោជន៍នៃឫស្សីនៅឧទ្យានមិនត្រឹមផ្ដល់ដល់មនុស្សប៉ុណ្ណោះទេ សត្វព្រៃមានដូចជា ប្រើស ក៏ចូលចិត្តស៊ីទំពាំងឫស្សីដែរ។ ឫស្សីគឺជាចំណែកមួយនៃការធ្វើឱ្យមានគម្របបៃតងដែលជាភ្នាក់ងារជួយដល់បរិស្ថាន និងលំនឹងបរិស្ថានដែរ។

ឫស្សីជារុក្ខជាតិមួយប្រភេទដែលមនុស្សយកមកដាំជាគ្រឿងលំអដែរ។ គេច្រើនដាំជារបង ឬជាប់នឹងផ្លូវចូល ឬនៅតាមសងខាងផ្លូវ។ ដូចនៅបណ្ដុំទួលសន្លុងឫស្សីត្រឹប និងបណ្ដុំទួលសន្លុងត្រពាំងឫស្សីត្រឹប ឫស្សីជាចំណែកលំអមួយដល់ទីតាំងនេះ ព្រោះទួលសន្លុងមិនមែនជាប្រាសាទដែលទាក់ទាញភ្នែកអ្នកទេសចរទេ ប៉ុន្តែដោយសារមានដើមឫស្សីដុះជាច្រើន ធ្វើឱ្យបណ្ដុំទួលសន្លុងមានសម្រស់មួយបែប។

## សេចក្ដីសន្និដ្ឋាន

ឫស្សីនៅឧទ្យានរាជបណ្ឌិត្យសភាកម្ពុជា តេជោសែន ឫស្សីត្រឹប ដុះនៅទីតាំងដែលមានទួលសន្លុងស្លដែកប៉ុណ្ណោះ។ ឫស្សីទាំងនោះមានបួនប្រភេទគឺឫស្សីឃ្លៃលលក ឫស្សីទ្រនំមាន់ ឫស្សីសាញ និងឫស្សីធម្មតា ខុសពីឫស្សីពូជក្នុងស្រុកផ្សេងទៀត ដែលមានឈ្មោះ ដូចជាឫស្សីព្រៃ ឫស្សីពីងពុង ឫស្សីព្រៃ ឫស្សីរលៀក...។ល។ ប៉ុន្តែនៅពេលថ្មីៗនេះ គេនាំយកពូជឫស្សីពីបរទេសដោយមានពីប្រទេសចិនផង ដូចជាឫស្សីទំពាំងផ្អែមដែលគេកំពុងពេញនិយមដាំច្រើន។ ទោះបីពូជខុសគ្នាឬឈ្មោះមិនដូចគ្នា តែយ៉ាងណាអត្ថប្រយោជន៍នៃឫស្សីមិនខុសគ្នាទេ សំខាន់មនុស្សចេះកែច្នៃទាញយកអត្ថប្រយោជន៍ពីឫស្សីបាន។ បច្ចុប្បន្ន ព្រៃឈើដែលជាតម្រូវការរបស់មនុស្សកាន់តែមានបរិមាណតិចៗទៅ ហើយទៅថ្ងៃអនាគតនឹងមិនអាចបំពេញសេចក្ដីត្រូវការប្រើប្រាស់របស់មនុស្សបានឡើយ។ នៅប្រទេសកេនយ៉ា ក្នុងទ្វីបអាហ្វ្រិក កំពុងជំរុញឱ្យស្ថាប័នពាក់ព័ន្ធ និងវិស័យឯកជនខាងកសិកម្មឱ្យអភិវឌ្ឍការដាំដើម

---

[11] កិច្ចសម្ភាសន៍ជាមួយឯកឧត្តម សូត្រ សំណាង ប្រធានឧទ្យានរាជបណ្ឌិត្យសភាកម្ពុជា តេជោសែន ឫស្សីត្រឹប។

[12] ជារៀងរាល់រដូវធ្វើនំក្រឡាន នៅរដូវច្រូតកាត់រួច (ខែវិច្ឆិកា និងខែធ្នូ) បងប្អូនប្រជាពលរដ្ឋនៅឃុំឆែប១ និងឆែប២ ស្រុកឆែប ខេត្តព្រះវិហារ ធ្វើនំក្រឡានបរិភោគដែលគ្រឿងផ្សំខុសពីនំក្រឡាននៅតំបន់ខេត្តផ្សេងៗទៀតក្នុងប្រទេសកម្ពុជា ដូចជាប្រើល្ង និងសណ្ដែកកត្តិកពិសេសមានទំហំធំខុសប្លែកពីនំក្រឡាននៅស្រុកខេត្តផ្សេងៗដែរ។

ឫស្សីសម្រាប់ជំនួសការប្រើប្រាស់ឈើដែលកំពុងបាត់បង់[13]។ ស្របពេលគ្នានេះដែរ ឫស្សីអាចជំនួសឈើក្នុងតម្រូវការជាច្រើនបាន។ ដូច្នេះ ការដាំដុះឫស្សីបន្ថែមលើផ្ទៃដីទំនេរ អាចបង្កើតឱ្យមានគម្របបៃតងជួយដល់បរិស្ថានព្រមទាំងអត្ថប្រយោជន៍ផ្សេងៗទៀត។

ឫស្សីនៅប្រទេសចិនដុះតាំងពី៧០០០ឆ្នាំមុនគ្រិស្តសករាជ[14]។ ដោយឡែកនៅប្រទេសកម្ពុជាមិនមានការសិក្សាបែបវិទ្យាសាស្ត្របង្ហាញពីអាយុកាលឫស្សីដុះដំបូងនៅឡើយ។ អត្ថបទនេះមិនបានពិចារណាដល់ពេលណាដែលឫស្សីនៅឧទ្យានរាជបណ្ឌិត្យសភា តេជោសែន ឫស្សីត្រឹប ចាប់ផ្តើមដុះនោះទេ។ ប៉ុន្តែ យើងឆ្ងល់ថា តើពេលណាដែលឫស្សីចាប់ផ្តើមដុះក្នុងទឹកដីឧទ្យានរាជបណ្ឌិត្យសភាកម្ពុជា តេជោសែន ឫស្សីត្រឹប? និងសាកល្បងស្នើសម្មតិកម្ម ថា «តើអ្នកស្លដែក និងស្មិតដែកនៅទីនេះ ប្រើធ្យូងឫស្សីសម្រាប់ស្លដែក និងលត់ដែកដែរឬទេ?»។ សម្មតិកម្មនេះអាចប្លែកបន្តិច តែរហូតមកដល់ពេលនេះ ទាំងអ្នកស្រាវជ្រាវជាតិ ទាំងអ្នកស្រាវជ្រាវអន្តរជាតិ កំពុងព្យាយាមសិក្សាស្រាវជ្រាវរកប្រភេទឈើ ដែលគេបានយកមកធ្វើធ្យូងសម្រាប់ស្លរំលាយរ៉ែដែកនៅសម័យបុរាណហើយដែលក៏ពុំទាន់រកឃើញនៅឡើយ។ កន្លងមក ពុំមានអ្នកស្រាវជ្រាវណាម្នាក់បានគិតដល់សម្មតិកម្មនេះឡើយ។ ការណ៍ដែលធ្វើឱ្យយើងលើកសម្មតិកម្មនេះឡើង ដោយសារ ១-ឫស្សីនៅក្នុងឧទ្យានដុះនៅតែក្នុងបណ្តុំទួលសន្លងស្លដែកតែប៉ុណ្ណោះ, ២-នៅសម័យបច្ចុប្បន្ន គេក៏យកធ្យូងធ្វើពីឫស្សីមកប្រើប្រាស់សម្រាប់ដុតកម្តៅដែរ ហើយកម្តៅទៀតសោតក៏មានកម្តៅខ្លាំងជាងធ្យូងដើមឈើដទៃទៀត។ ការសិក្សាស្រាវជ្រាវមួយគួរត្រូវអនុវត្តតាមបែបវិទ្យាសាស្ត្រដើម្បីបកស្រាយសម្មតិកម្មខាងលើ ព្រមទាំងបង្ហាញថា ឫស្សីមានការប្រើប្រាស់ក្នុងពេលណាមួយ ឬក៏អាចប្រើកែច្នៃជាធ្យូងសម្រាប់ដុតរំលាយរ៉ែដែកដើម្បីទាញយកដែកមកប្រើ។

យើងខ្ញុំសូមផ្តល់អនុសាសន៍ដល់ឧទ្យានរាជបណ្ឌិត្យសភាកម្ពុជា តេជាសែន ឫស្សីត្រឹប គួរគ្រប់គ្រងមរតកឫស្សីដែលមានស្រាប់ និងអភិវឌ្ឍដំណាំឫស្សីដែលអាចជាទិសដៅអាទិភាពមួយ ដោយដាំឫស្សីនៅទីតាំងដីណាដែលមិនសូវមានដីជាតិ និងមានដើមឈើដុះរង្វើលៗ ដោយឫស្សីជាប្រភេទរុក្ខជាតិងាយដាំ មិនរើសដី ហើយអាចដាំដុះជាមួយរុក្ខជាតិផ្សេងៗទៀតបាន ទុកជាអត្តសញ្ញាណមួយនៃតំបន់ឧទ្យានរាជបណ្ឌិត្យសភាកម្ពុជា តេជាសែន ឫស្សីត្រឹប ហើយអាចទាញផលឫស្សីយកមកកែច្នៃតាមតម្រូវការផ្សេងៗ ក៏ដូចជាបន្តជួយសហគមន៍ឱ្យមានឫស្សីប្រើប្រាស់ជារៀងរហូត៕

[13] Kigomo, Bernard N., *Guidelines for Growing Bamboo*, KEFRI Guideline Series: No. 4-April 2007, Kenya Forestry Research Institute, 2007

[14] http://www.chinatoday.com/culture/bamboo_and_chinese/bamboo_and_chinese_culture.htm

## ឯកសារយោង


ព្រះរាជក្រឹត្យលេខ នស/រកត/០៤១៤/៤៣៦ ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១៤ស្តីពី *ការបង្កើតឧទ្យានរាជបណ្ឌិត្យសភាកម្ពុជា តេជោសែន ឫស្សីត្រឹប*

នូ ចាន់សុភី, ផុន កសិកា, ប្រែង ពិសិដ្ឋ... «*សម្បត្តិបេតិកភណ្ឌវប្បធម៌រូបីនិងមរតកវប្បធម៌អរូបី នៅឧទ្យានរាជបណ្ឌិត្យសភាកម្ពុជា តេជោសែន ឫស្សីត្រឹប និងការសិក្សាអង្កេតមរតកវប្បធម៌អរូបីដូចគ្នានៅខេត្តកំពង់ធំ ខេត្តស្ទឹងត្រែង និងខេត្តក្រចេះ*», វិទ្យាស្ថានវប្បធម៌ និងវិចិត្រសិល្បៈ, រាជបណ្ឌិត្យសភាកម្ពុជា, ២០១៨

វចនានុក្រមខ្មែរ, បោះពុម្ពលើកទី៥

កិច្ចសម្ភាសន៍ជាមួយឯកឧត្តម សូត្រ សំណាង ប្រធានឧទ្យានរាជបណ្ឌិត្យសភាកម្ពុជា តេជោសែន ឫស្សីត្រឹប

កិច្ចសម្ភាសន៍លោក សួង សាត ប្រជាពលរដ្ឋរស់នៅក្នុងភូមិធែបលិច ឃុំធែប១ ស្រុកធែប ខេត្តព្រះវិហារ

Bernard N. Kigomo, *Guidelines for Growing Bamboo*, KEFRI Guideline Series: No. 4-April 2007, Kenya Forestry Research Institute, 2007

https://www.usaid.gov/cambodia/environment-and-global-climate-change

http://www.geres.eu/en/development-of-a-sustainable-bamboo-charcoal-production-center

https://globalfoodbook.com/28-incredible-benefits-of-the-bamboo-plant

http://www.chinatoday.com/culture/bamboo_and_chinese/bamboo_and_chinese_culture.htm